សំរង់ព័ត៌មានប្រចាំសប្តាហ៍

# ស្ថានភាពកុមារនៅកម្ពុជា

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ

ឆ្នាំទី១ លេខ ៤ ថ្ងៃទី១២ ដល់ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៥

មាតិកា ទំព័រ

ឪពុកចុងចាប់រំលោភកូនដើម អាយុ១៣ឆ្នាំ........................១

តាអាយុ៦៣ឆ្នាំរំលោភក្មេងស្រី អាយុ៨ឆ្នាំត្រូវជាប់គុក១០ឆ្នាំ...........២

សំណុំរឿងចាប់រំលោភក្មេងស្រីកប់បាត់រហូតកើតបានកូន................២

ប្រមូលក្រុមក្មេងស្ទាវញៀនថ្នាំដើរបង្កអុកឡុកកាត់កាច់គាស់.............៣

ប្រជាពលរដ្ឋសង្កាត់បឹងកេងកង២ ព្រួយបារម្ភពីសកម្មភាពចែកចាយ.......៤

បុរសកូន៤ចាប់រំលោភកុមារីអាយុ ១៦ឆ្នាំពេលឃ្វាលក្របី.................៤

ពួកកុមារក្រីក្រនៅតាមជនបទរៀនផងឆ្លៀតស៊ីឈ្នួលវាយថ្មផង............៥

វាសនាក្មេងអ្នកដើរសុំទាននៅខេត្តតាកែវ...........................៦

ខេត្តព្រៃវែងប្រជាពលរដ្ឋជាង៦ម៉ឺននាក់ធ្វើចំណាកស្រុក..................៦

ដេកគុកដោយសារសើយសំពត់កូនស្រី និងប្រើអំពើហិង្សាលើភរិយា.......៧

ទារលុយប្រពន្ធ៣០$មិនបានចាប់ទាំងប្រពន្ធ និងកូនពីរនាក់ចង.........៧

## ឪពុកចុងចាប់រំលោភកូនដើមអាយុ១៣ឆ្នាំ

ក្មេងស្រីកំព្រាម្នាក់ត្រូវបានរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយសារឪពុកចុងចាប់រំលោភសេពសន្ថវៈជាបន្តបន្ទាប់។ រឿងនេះបានបែកការនៅពេលអ្នកស្រុកឃើញក្មេងស្រីរងគ្រោះធ្វើដំណើរខុសប្រក្រតី។

ក្មេងស្រីរងគ្រោះត្រូវឪពុកចុងចាប់រំលោភជាបន្តបន្ទាប់ចំនួន៥លើកនៅឃុំត្រពាំងសាប ស្រុកទន្លេបាទី ខេត្តតាកែវ។

ប៉ូលិសបានចាប់ខ្លួនឪពុកចុងតាមពាក្យបណ្តឹងរបស់ម្តាយមីងក្មេងស្រីរងគ្រោះកាលពីថ្ងៃទី៨ សីហា ២០០៥។

លោក ង៉ាន់ សារី អធិការស្រុកទន្លេបាទីប្រាប់ឱ្យដឹងថា ឪពុកចុងឈ្មោះ ស.ហ អាយុ ៦១ឆ្នាំ ឯកុមារីរងគ្រោះឈ្មោះ ឆ.ត្រ អាយុ១៣ឆ្នាំ។ ក្មេងស្រីបានរៀបរាប់ប្រាប់ប៉ូលិសថា ឪពុកបង្កើតរបស់នាងបានលែងគ្នាជាមួយម្តាយយូរមកហើយ។ បន្ទាប់មកម្តាយរបស់នាងមានប្តីឈ្មោះស.ហនេះមានកូនចំនួន២នាក់ទៀត។ រហូតមកដល់ខែមេសា ២០០៥ ម្តាយនាងឈឺក៏បានស្លាប់ទៅ។ ក្រោយពេលម្តាយស្លាប់រូបនាងបានមករស់នៅជាមួយឈ្មោះអ៊ុន សែន ភេទស្រី អាយុ៦០ នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

ក្មេងស្រីបន្តថា មុនពេលកើតហេតុកន្លះខែ ឪពុកចុងបានផ្តាំតាមគេឱ្យរូបនាងមកលេងប្អូនបានពីរបីថ្ងៃ រូបនាងក៏មកតាមពាក្យផ្តាំ។ នៅពាក់កណ្តាលយប់ថ្ងៃមកដល់ដំបូង ឪពុកចុងបានចាប់រំលោភបានសំរេច ហើយបានគំរាមមិនឱ្យនាងប្រាប់គេ បើហ៊ានប្រាប់គាត់នឹងសំលាប់ចោល។ ក្មេងស្រីបញ្ជាក់ថា ឪពុកចុងបានចាប់រំលោភសេពសន្ថវៈលើរូបនាងជាបន្តបន្ទាប់ ជួនពេលយប់ ជួនពេលថ្ងៃឱ្យតែស្ងាត់។

ស្ត្រីម្នាក់ឈ្មោះ ពេជ លក់ចាប់ហួយនៅភូមិកើតហេតុបាននិយាយប្រាប់ប៉ូលីសថា គាត់ឃើញក្មេងស្រីរងគ្រោះដើរខុសពីប្រក្រតី នឹកឆ្ងល់ក៏ជជីកសួររកមូលហេតុ ក្មេងស្រីបានប្រាប់ថា រូបនាងត្រូវឪពុកចុងចាប់រំលោភ។ ពេលដឹង

រឿងហើយគាត់ក៏បានទៅប្រាប់ម្តាយមីង កុមារីរងគ្រោះ ហើយបានប្តឹងប៉ូលិសឱ្យចាប់ខ្លួនជនល្មើសនៅថ្ងៃទី៨ សីហាតែម្តង។

នៅចំពោះមុខប៉ូលិស ឪពុកចុងបានសារភាពថា រូបគេពិតជាបានចាប់រំលោភកូនស្រីដើមពិតប្រាកដមែន គឺបានសំរេចចំនួន៥ដង ដោយនិយាយលួងលោមផង និងនិយាយគំរាមកំហែងផង ទើបចាប់រំលោភបានសំរេច។

ជនល្មើសត្រូវបានប៉ូលីសនៃស្នងការនគរបាលខេត្តកសាងសំនុំបែបបទបញ្ជូនទៅតុលាការកាត់ទោសតាមច្បាប់៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៥១*
*ថ្ងៃទី ១២_០៨_០៥*

# តាអាយុ៦៣ឆ្នាំរំលោភក្មេងស្រីអាយុ៨ឆ្នាំត្រូវជាប់គុក១០ឆ្នាំ

នៅក្នុងអង្គសវនាការដែលធ្វើឡើងនៅថ្ងៃទី១២ សីហា ២០០៥នេះ តុលាការបានសំរេចផ្តន្ទាទោសតាអាយុ៦៣ឆ្នាំដាក់គុកចំនួន១០ឆ្នាំ និងបង់ប្រាក់ពិន័យ១លានរៀល ពីបទរំលោភសេពសន្ថវៈលើក្មេងស្រីអាយុ៨ឆ្នាំ។

គួររំលឹកថា តាឆឹម ឡាត់បានរំលោភកុមារីឈ្មោះខ.ច.ឧនៅលើអង្រឹងដែលចងក្រោមផ្ទះកុមារីរងគ្រោះនៅភូមិថ្កោលធំ ឃុំអន្សាចំបក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់។ រីឯផ្ទះជនល្មើសនៅក្បែរផ្ទះជនរងគ្រោះដែរ។ ការរំលោភសេពសន្ថវៈនេះប្រព្រឹត្តទៅនៅថ្ងៃទី២៨ មីនា ២០០៥។

តាចាស់រូបនេះបានឆ្លើយប្រាប់តុលាការថា ខ្លួនពិតជាបានរំលោភក្មេងស្រីនោះប្រាកដមែន ដោយសារពេលនោះខ្លួនមានការស្រវឹង ហើយក្មេងស្រីនោះបានមកដេកទ្រាបពីលើទើបធ្វើឱ្យមានអារម្មណ៍។ ប៉ុន្តែការរំលោភនោះមិនបានសំរេចទេ ដោយសារតែក្មេងស្រីយំ។

ម្តាយក្មេងស្រីរងគ្រោះនិយាយថា ពេលតាឆឹមឡាត់ រំលោភកូនគាត់នោះ គឺគាត់មិននៅផ្ទះទេ ដោយជាប់រវល់ហាលស្រូវ តែត្រូវបានគេរត់ទៅប្រាប់គាត់។ ពេលគាត់មកដល់ផ្ទះក៏ឃើញតាឆឹមឡាត់ដេកលើអង្រឹងក្រោមផ្ទះគាត់ស្រែកច្រៀងធ្វើមិនដឹង រីឯកូនរបស់គាត់បានយំរហូត។ ពេលឱ្យពេទ្យពិនិត្យឃើញប្រដាប់ភេទមានការហើមប៉ោង។

នៅក្នុងសវនាការមានវត្តមានទាំងជនល្មើស និងជនរងគ្រោះ ប៉ុន្តែអង្គការដែលការពារស្ត្រី និងកុមារដែលរងគ្រោះមិនឃើញវត្តមានទេ ប៉ុន្តែតុលាការបានធ្វើការងាររបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៥២*
*ថ្ងៃទី ១៣_០៨_០៥*

# សំណុំរឿងចាប់រំលោភក្មេងស្រីកប់បាត់រហូតកើតបានកូនមួយមិនទាន់ស៊ើបអង្កេត

ក្មេងស្រីម្នាក់អាយុ១៥ឆ្នាំនៅភូមិទួលអង្គប់ ឃុំសំបួរ ស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលទទួលរងការចាប់រំលោភសេពសន្ថវៈយ៉ាងព្រៃផ្សៃរហូតមានផ្ទៃពោះនោះ ឥឡូវនេះនាងសម្រាលបានកូនស្រីមួយហើយ ប៉ុន្តែជនល្មើសនៅពុំទាន់ចាប់ខ្លួនផ្តន្ទាទោសតាមច្បាប់នៅឡើយ ដោយសារពាក្យបណ្តឹងរបស់ឪពុកក្មេងស្រីរងគ្រោះកប់បាត់ឈឹងនៅស្នងការនគរបាលខេត្ត។

មន្ត្រីប៉ូលិសការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តបាននិយាយថា ករណីខាងលើនេះសមត្ថកិច្ចនឹងចុះស៊ើបអង្កេតក្នុងពេលឆាប់ៗនេះ។

តាមការរៀបរាប់របស់ម្តាយជនរងគ្រោះថា នៅវេលាម៉ោង១០ព្រឹកថ្ងៃទី១៨ ខែធ្នូ ២០០៤ កូនគាត់ឈ្មោះព.ស.ស.ម កំពុងអង្គុយមើលទូរទស្សន៍ក្នុងផ្ទះម្នាក់ឯងឪពុកម្តាយនិងកូនៗ៤នាក់ទៀតមិននៅផ្ទះ គឺទៅលេងផ្ទះបងប្អូនក្នុងភូមិស្រាប់តែឈ្មោះអ.ស.ណអាយុ៣១ឆ្នាំនៅភូមិ_ឃុំជាមួយគ្នាបានចូលទៅចាប់កូនស្រីគាត់រំលោភរហូតបានសំរេច។ ក្រោយពីរំលោភបានសំរេចហើយជនល្មើសបានគំរាមកូនស្រីគាត់ថា បើហ៊ានប្រាប់គេឱ្យដឹងរឿងនេះគេនឹងសំលាប់ចោល។ ដោយភាពឆោតល្ងង់ និងភ័យខ្លាចកូនស្រីគាត់បានលាក់រឿងនេះរហូតដល់ថ្ងៃទី៣ ខែមេសា ២០០៤ទើបហ៊ានប្រាប់គាត់ថា នាងមានផ្ទៃពោះ៤ខែ។ លុះដល់ថ្ងៃទី៧ មេសា ២០០៥ គាត់បានដាក់ពាក្យបណ្តឹងទៅតុលាការខេត្ត ហើយលោកព្រះរាជអាជ្ញាបានបញ្ជូនសំណុំរឿងទៅស្នងការនគរបាលខេត្ត ដើម្បីស៊ើបអង្កេត។

មន្ត្រីអង្គការសម្ព័ន្ធអ្នកសង្គ្រោះ

បុថុជ្ជន(CSP) ខេត្តស្វាយរៀងបានឱ្យដឹងថា បុគ្គលិករបស់អង្គការបានចុះទៅជួបផ្ទាល់ជាមួយក្មេងស្រីរងគ្រោះដល់លំនៅស្ថានឃើញថា គ្រួសារនេះពិតជាក្រីក្រលំបាកណាស់។ ថ្វីត្បិតនាងបានសំរាលកូនហើយក្តី ឬក៏ភាគីខាងប្រុសព្យាយាមដោះសាថា ពុំបានប្រព្រឹត្តឬដោយមានការព្រមព្រៀងគ្នាក៏ដោយ ក៏ផ្នែកកុមារនៃអង្គការCSPប្តឹងទៅស្នងការនគបាលខេត្ត ដើម្បីជួយអន្តរាគមន៍ និងចាត់ការស៊ើបអង្កេតតាមផ្លូវច្បាប់។

លោកស្វ ម៉ាលីស អនុប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តបានឱ្យដឹងថា ករណីខាងលើសមត្ថកិច្ចនឹងចុះស៊ើបអង្កេតក្នុងពេលឆាប់ៗនេះតាមបណ្តឹងអន្តរាគមន៍របស់អង្គការCSP។

សំណុំរឿងរបស់ជនរងគ្រោះត្រូវបានផ្អឹបទុករហូតនាងសម្រាលកូនរួចនៅពុំទាន់មានការស៊ើបអង្កេត។ ចាំមើលជនល្មើសដែលមានទាំងប្រពន្ធកូនហើយទៅចាប់រំលោភក្មេងស្រីអាយុ១៥ឆ្នាំរហូតបានមានផ្ទៃពោះកើតបានកូនស្រីមួយទៀត តើអាចគេចផុតពីសំណាញ់ច្បាប់ដែរឬទេ៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៥២*
*ថ្ងៃទី១៣_០៨_០៥*

# ប្រមូលក្រុមក្មេងស្ទាវញៀនថ្នាំដើរបង្កអុកឡុកកាត់កាច់គាស់លួចទ្រព្យគេក្នុងប្រជុំជនខេត្ត

ក្រុមក្មេងស្ទាវមួយសម្បុកមានគ្នា៨នាក់ ដែលចែកជាក្រុមដែដល់បង្កបទល្មើសជាក់ស្តែង និងក្រុមធ្លាក់ខ្លួនអនាថាអាវ៉ាសែត្រូវកំលាំងអាវុធហត្ថខេត្តបន្ទាយមានជ័យ ប្រមូលចាប់ខ្លួន ក្នុងនោះ៥នាក់ត្រូវបញ្ជូនទៅតុលាការថ្ងៃទី១០ សីហានេះ និង៣នាក់អប់រំណែនាំរួចបញ្ជូនទៅលំនៅស្ថានវិញ។

លោកឱ ប៉ូរិន បញ្ជាការរងកងអាវុធហត្ថខេត្តបន្ទាយមានជ័យនិយាយនៅថ្ងៃទី១០ សីហាថា ក្មេងស្ទាវហិតការញៀនថ្នាំ ហើយដើរបង្កអុកឡុកក្នុងទីប្រជុំជនខេត្តបន្ទាយមានជ័យនៅពេលយប់ជ្រៅរាល់ថ្ងៃ ដូចជាលួចឆក់កាត់គាស់ កាច់សោផ្ទះ_ឃ្លាំង លួចយកទ្រព្យសម្បត្តិគេជាបន្តបន្ទាប់ ដែលធ្លាប់ចាប់ខ្លួនបញ្ជូនទៅតុលាការដើម្បីឃុំឃាំងតែបានអនុគ្រោះគឺនៅក្នុងគុកមួយរយៈក៏ដោះលែងឱ្យមានសេរីភាពវិញនោះត្រូវបានចាប់ខ្លួនជាថ្មីក្នុងរយៈពេល៣ថ្ងៃ(៧_៨_៩ សីហា)ជាបន្តបន្ទាប់ ដោយសារជនទាំងនោះមិនកែខ្លួន ហើយបង្កបទល្មើសថ្មីថែមទៀត។

លោកឱ ប៉ូរិនបន្តថា មូលហេតុនាំឱ្យចាប់ខ្លួនលើកនេះ គឺមកពីពួកគេរៀបចំ និងស្ថិតនៅរបងផ្សារសេរីសោភ័ណភូមិ៣ ឃុំព្រះពន្លា វេលាម៉ោង៩យប់ដើម្បីគាស់កាត់សោរបង និងឃ្លុបអីវ៉ាន់ក្នុងផ្សារ។

ក្មេងស្ទាវហិតការញៀនថ្នាំទាំង៨នាក់នោះ គឺ៥នាក់ជាជនដែដល់ប្រព្រឹត្តកាត់កាច់គាស់យកទ្រព្យសម្បត្តិគេគឺ ១_ឈ្មោះ ក.ធ ភេទប្រុស អាយុ២៣ឆ្នាំ ២_ឈ្មោះ ល.ច ភេទប្រុស អាយុ២៥ឆ្នាំ ៣_ឈ្មោះឈ.ច.ថ ហៅក ភេទប្រុស អាយុ១៥ឆ្នាំ ៤_ឈ្មោះទ.ក ភេទប្រុស អាយុ១៥ឆ្នាំ និង៥_ឈ្មោះ ហ.ខ.រ ហៅប ភេទប្រុស អាយុ១៥ឆ្នាំ។ ពួកគេគ្មានផ្ទះសំបែង និងអាណាព្យាបាលពិតប្រាកដទេ ហើយគេឧស្សាហ៍ឃើញនៅម្តុំរ៉ារថភ្លើងសេរីសោភ័ណ ភូមិ៤ ឃុំព្រះពន្លា។ ឯ៣នាក់ទៀត ជាក្រុមក្មេងធ្លាក់ខ្លួនជាអនាថាអាវ៉ាសែ រួមមាន ១_ឈ្មោះ ធ.ធ ភេទប្រុស អាយុ១៧ឆ្នាំ ២_ឈ្មោះស.ធ ភេទប្រុស អាយុ១៤ឆ្នាំ និង៣_ឈ្មោះ ឈ.ព ភេទប្រុស អាយុ១២ឆ្នាំ។ ពួកគេគ្មានអាណាព្យាបាលនិងទីលំនៅពិតប្រាកដដែរ។

លោកវ័ន្ត ស្រ៊ាង មេបញ្ជាការកងអាវុធហត្ថខេត្តបន្ទាយមានជ័យបានឱ្យដឹងថា ក្រុមក្មេងស្ទាវដែដល់៥នាក់ត្រូវបញ្ជូនទៅតុលាការ ឯ៣នាក់ទៀតត្រូវអប់រំណែនាំ រួចបញ្ជូនទៅអាណាព្យាបាលបណ្តោះអាសន្នរបស់ពួកគេវិញ។

លោកបន្តទៀតថា កន្លងមកក្រុមក្មេងស្ទាវទាំងនេះ និងបក្ខពួកជាច្រើនទៀត ធ្លាប់បង្កអុកឡុកនៅទីប្រជុំជនខេត្តនៅពេលយប់ជ្រៅ ដូចជាកាត់គាស់ លួចទ្រព្យសម្បត្តិគ្រប់ប្រភេទ។ បន្ថែមលើនោះ ពួកគេក្លាយជាក្មេងញៀនថ្នាំ តែពុំព្រមស្ថិតឱ្យគេអប់រំកែប្រែបន្សាប និងធ្លាប់ត្រូវសមត្ថកិច្ចចាប់ខ្លួនទៅតុលាការកាត់ទោសឃុំឃាំងមួយរយៈពេលខ្លីរួចមកហើយ។ ប៉ុន្តែពួកគេខ្លះជាអនីតិជនទើបពុំអាចស្ថិតនៅឃុំឃាំងយូរ។ លុះចេញមកវិញ ក៏ប្រព្រឹត្តអំពើអាវ៉ាសែហិតការញៀនថ្នាំដដែល៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៥១*
*ថ្ងៃទី១២_០៨_០៥*

# ប្រជាពលរដ្ឋសង្កាត់បឹងកេងកង២ព្រួយបារម្ភពីសកម្មភាពចែកចាយគ្រឿងញៀនដែលគ្មានការបង្ក្រាប

ដោយព្រួយបារម្ភបញ្ហាកូនចៅដែលស្ថិតនៅក្នុងវ័យជំទង់ ហើយសកម្មភាពចែកចាយគ្រឿងញៀនមានភាពយ៉ាងផុលផុសនៅក្នុងមូលដ្ឋានរបស់ខ្លួន នោះប្រជាពលរដ្ឋដែលស្ថិតនៅផ្លូវលេខ ២៩២ ក្នុងសង្កាត់បឹងកេងកង២ ខណ្ឌចំការមនបានសំណូមពរដល់លោកឧត្តមសេនីយ៍ត្រីហេង ពៅស្នងការប៉ូលិសក្រុងភ្នំពេញឱ្យជួយចាត់ការបញ្ហាទាំងនេះ។

ប្រជាពលរដ្ឋក្នុងសង្កាត់បឹងកេងកង២ ខណ្ឌចំការមន សុំមិនបញ្ចេញឈ្មោះបានប្រាប់រស្មីកម្ពុជាថា មានផ្ទះមួយនៅផ្លូវ២៩២សង្កាត់បឹងកេងកង២ បានធ្វើសកម្មភាពលក់ដូរគ្រឿងញៀនយ៉ាងសកម្មទាំងយប់ទាំងថ្ងៃជាយូរឆ្នាំមកហើយ ដោយមិនខ្លាចក្រែងសមត្ថកិច្ចមូលដ្ឋានបន្តិចណាឡើយ។ ក្រុមយុវជនប្រើប្រាស់គ្រឿងញៀនតែងតែមកពពាក់ពពូនទិញគ្រឿងញៀននៅទីនោះយកទៅប្រើប្រាស់ ហើយធ្លាប់បានបង្ករឿងឈ្លោះប្រកែកគ្នារកតែប្រជាពលរដ្ឋសម្រាកមិនបាន។

ប្រភពនេះបន្តថាការលក់ដូរថ្នាំញៀននេះ មន្ត្រីមូលដ្ឋានដឹងយ៉ាងច្បាស់លាស់ណាស់ ប៉ុន្តែពុំឃើញមានការចុះបង្ក្រាបណាមួយឡើយនាពេលថ្មីៗនេះ។ ហើយទើបប្រជាពលរដ្ឋគ្មានជំនឿលើសមត្ថកិច្ចមូលដ្ឋាន។ ទោះបីយ៉ាងនេះក្តី ប្រជាពលរដ្ឋសង្ឃឹមថា លោកឧត្តមសេនីយ៍ត្រីហេង ពៅនឹងជួយចាត់វិធានការចំពោះបញ្ហានេះ ហើយប៉ូលិសណាដែលយកផ្ទះចែកចាយថ្នាំញៀនធ្វើជាផ្ទាំងបាំងរបស់ខ្លួននោះ ពិតជានឹងមិនស្រួលខ្លួនឡើយ។

ប្រភពដដែលបញ្ជាក់ថា ផ្ទះចែកចាយថ្នាំញៀននេះជាមុខសញ្ញាចាស់ ហើយគេឃើញប៉ូលិសចេញចូលយ៉ាងញឹកញាប់។ រីឯសកម្មភាពចែកចាយថ្នាំញៀនក៏កាន់តែមានសកម្មភាពខ្លាំងឡើងៗជាលំដាប់។ កន្លងមកគេលក់ដូរថ្នាំញៀនតែនៅពេលយប់កណ្តាលអធ្រាត្រតែប៉ុណ្ណោះ ប៉ុន្តែឥឡូវគេលក់ទាំងថ្ងៃ ដោយមានសមាជិកគ្រួសារឈរលក់នៅតាមផ្លូវ ឬនៅក្នុងផ្ទះតែម្តង។ បញ្ហាទាំងនេះប្រជាពលរដ្ឋដែលមានកូនចៅស្ថិតក្នុងវ័យជំទង់កំពុងមានការព្រួយបារម្ភណ៍យ៉ាងខ្លាំងព្រោះបើមិនបង្ក្រាបថ្ងៃនេះទេវានឹងអាចរាលដាលដល់កូនចៅរបស់ខ្លួនតាមរយៈមិត្តភក្តិដែលងុបងុលដោយថ្នាំញៀន។

មុខសញ្ញាខាងលើប៉ូលិសធ្លាប់ចុះបង្ក្រាប២ទៅ៣លើករួចមកហើយនាប៉ុន្មានឆ្នាំមកនេះ ប៉ុន្តែពួកគេ(ជនជាប់ចោទ)មិនត្រូវបានច្បាប់ផ្តន្ទាទោសឡើយ។ ទំនងដោយសារបញ្ហានេះទើបមុខសញ្ញាហ៊ានវាយលុកទៅលើមុខរបរខាងលើកាន់តែខ្លាំងក្លាថែមទៀតយ៉ាងនេះ៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៥២*
*ថ្ងៃទី១៣_០៨_០៥*

# បុរសក្មួន៤ចាប់រំលោភកុមារីអាយុ១៦ឆ្នាំពេលឃ្វាលក្របី

កុមារីរងគ្រោះត្រូវបានឪពុកនិងម្តាយធំនាំមកកាន់ការិយាល័យសមាគមការពារសិទ្ធិមនុស្សអាដហុក កាលពីព្រឹកថ្ងៃទី១៥ សីហា ២០០៥នេះ ដើម្បីធ្វើពាក្យបណ្តឹងប្តឹងបុរសម្នាក់ដែលបានចាប់រំលោភនាងកាលពីថ្ងៃទី១ កក្កដា ២០០៥។ ក្រុមគ្រួសារនារីរងគ្រោះបានអះអាងថា បានប្តឹងប៉ូលិសអស់រយៈពេលជាង១ខែមកហើយ តែមិនឃើញប៉ូលិសចាត់ការអ្វីសោះ។

មន្ត្រីសិទ្ធិមនុស្សបាននាំកុមារីរងគ្រោះទៅឱ្យគ្រូពេទ្យពិនិត្យហើយ តែមិនទាន់បានទទួលលទ្ធផលនៅឡើយ។

ម្តាយធំកុមារីរងគ្រោះអះអាងថា កុមារីរងគ្រោះមានអាយុ១៦ឆ្នាំ រស់នៅឃុំគោល ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។ នាងជាមនុស្សមិនគ្រប់លក្ខណៈទេហើយស្ងួរមិនចង់និយាយទេ។

គាត់បន្តថាកាលពីថ្ងៃទី១កក្កដា ២០០៥ វេលាម៉ោង៣រសៀល នារីរងគ្រោះត្រូវបុរសម្នាក់ឈ្មោះអ. ឃ អាយុ ៣៥ឆ្នាំ រស់នៅភូមិទួលចារ ឃុំគោល ចាប់រំលោភនាងរហូតបានសម្រេចនៅតំបន់ថ្មទទឹង ភូមិទួលចារ ខណៈពេលដែលនាងទៅមើលក្របី។

ម្តាយធំបន្តទៀតថា ក្រោយពេលរំលោភបាន៤ថ្ងៃទើបគាត់ដឹង ហើយបានទៅប្តឹងមេភូមិ មេភូមិបានអន្តរាគមន៍ទៅមេឃុំ បន្ទាប់មកមេឃុំបញ្ជូនទៅមេប៉ុស្តិ៍

*តទៅទំព័រទី៥*

*តមកពីទំព័រទី៤*

ទើបប៉ូលិសចុះទៅសួរនាំធ្វើកំណត់ហេតុ ប៉ុន្តែរហូតមកដល់ពេលនេះ ជនជាប់ចោទមិនត្រូវបានកោះហៅទៅសាកសួរអ្វីទាំងអស់ ហើយរឿងនេះក៏កប់បាត់រហូតមក។

ឪពុកជនរងគ្រោះនិយាយថា គាត់ពុំមានសាក្សីឃើញផ្ទាល់ភ្នែកទេ តែពួកគាត់ដឹងនៅពេលដែលដេញកូនឱ្យទៅមុជទឹក តែកូននិយាយថាមិនហ៊ានទៅព្រោះខ្លាចអាអ.យចាប់។ ពួកគាត់ក៏សន្និដ្ឋានថាកូនគាត់ត្រូវឈ្មោះអ.យចាប់រំលោភមែន។ ម្យ៉ាងទៀតដោយឈ្មោះអ.យនេះធ្លាប់មានប្រវត្តិមិនល្អផង។

លោក ភោគ លី អធិការរងស្រុកប្រាសាទសំបូរនិយាយថា លោកបានទទួលរបាយការណ៍មកពីប៉ុស្តិ៍ខ្លះៗហើយ ប៉ុន្តែមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ ហើយលោកកំពុងឱ្យប៉ុស្តិ៍បំពេញបែបបទបន្ថែមឱ្យគ្រប់និតិវិធីសិន។

នៅខេត្តកំពង់ធំ បន្ទាប់ពីបទល្មើសលួច ប្លន់ ចាប់ជំរិតបានស្ងប់ស្ងាត់ទៅ បទល្មើសរំលោភបានកើតឡើងជាបន្តបន្ទាប់ ផុតពីស្រុកមួយចូលស្រុកមួយ ប៉ុន្តែមានករណីខ្លះក៏ព្រោះតែចង់បានលុយកាក់ក៏ប្ដឹងចោទប្រកាន់ដាក់គ្នាក៏មានដែរ៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៥៥*
*ថ្ងៃទី១៧_០៨_០៥*

---

# ពួកកុមារក្រីក្រនៅតាមជនបទរៀនផងឆ្លៀតស៊ីឈ្នួលវាយថ្មផងដើម្បីស្រោចស្រង់ជីវភាព

ពួកកុមារា_កុមារីភាគច្រើនដែលរស់នៅតាមជនបទចុងកាត់មាត់ញក ហើយក្រុមគ្រួសាររបស់ពួកគេមានជីវភាពក្រីក្រ ក្រោយពេលទំនេរពីការរៀនសូត្រ ពួកគេឆ្លៀតជួយធ្វើការងារផ្ទះដូចជាឃ្វាលគោ រកអុស បេះបន្លែ រកក្ដាម ខ្យង ត្រី សាច់ តាមតំរូវការរបស់ក្រុមគ្រួសារ។ ដោយឡែកពួកកុមាររស់នៅក្នុងតំបន់ភូមិខ្លាកូនថ្មី ឃុំកំពង់ស្វាយ ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ បានស្រុះស្រួលគ្នាស៊ីឈ្នួលវាយថ្មឱ្យថៅកែដើម្បីជួយស្រោចស្រង់ជីវភាពគ្រួសារ និងចង់បានលុយយកទៅរៀនសូត្រចេះដឹងដូចកូនចៅអ្នកទីក្រុងដែរ។

តាមធម្មតាពួកគេដែលរស់នៅតាមជនបទមានទំលាប់មួយខុសពីកុមារទីក្រុង គឺពួកគេមិនសូវទុកពេលឱ្យទំនេរឥតប្រយោជន៍នោះទេ ចេញពីសាលារៀនភ្លាមក្រោយពេលញ៉ាំបាយរួចខ្លះទៅឃ្វាលគោ ខ្លះទៅរកអុស រកក្ដាមខ្យង។ ចំពោះកុមារដែលមានក្រុមគ្រួសារមានជីវភាពក្រីក្រខ្លាំង ឪពុកម្ដាយបានបង្ខំឱ្យពួកគេជួយវាយថ្មដោះស្រាយជីវភាពប្រចាំថ្ងៃ មិនសូវបានរៀនសូត្រនឹងគេទេ គឺមួយថ្ងៃទៅមួយថ្ងៃគេត្រូវបញ្ចេញញើសស្ទើរអស់ពីខ្លួនក្រោមកំដៅថ្ងៃព្រិចៗគួរឱ្យស្រណោះពន់ពេក។

កុមារី មុត ចន្ថា មុត ចន្ទីនិងកុមារាទី ខេង រស់នៅភូមិខ្លាកូនថ្មី ឃុំកំពង់ស្វាយ ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យបានឱ្យដឹងថា ជារៀងរាល់ថ្ងៃមិនថា ក្ដៅរីត្រជាក់ទេ ក្រោយពេលត្រឡប់ពីសាលារៀនភ្លាម គឺត្រូវចាប់ពូថៅរីញញួរដើម្បីវាយបំបែកថ្មតាំងពីថ្ងៃត្រង់រហូតដល់យប់ គ្មានចន្លោះថ្ងៃណាមួយទេ។ នៅពេលវ៉ាកងនេះទៀតសោតពួកយើងខ្ញុំចង់រៀនគួរនឹងគេដែរតែគ្មានលុយសោះ ហើយត្រូវបង្ខំចិត្តវាយថ្មតាំងពីព្រលឹមទល់ព្រលប់ ដើម្បីជួយគ្រួសារលក់យកលុយទិញអង្ករប្រេកឆ្នាំង ទិញម្ហូបអាហារ និងចង់បានលុយខ្លះទិញសំលៀកបំពាក់ សៀវភៅ ប៊ិកទៅរៀននឹងគេ។

ពួកកុមារទាំងនោះបានបន្តថា ទោះបីជាការវាយថ្មវាត្រូវចំណាយកំលាំងអស់ច្រើននៅក្រោមកំដៅថ្ងៃយ៉ាងណាក្ដី ក៏ក្នុងអារម្មណ៍របស់ពួកយើងខ្ញុំមិនដែលធុញថប់នឿយណាយនោះទេ ការងារទាំងនេះបានក្លាយជាទំលាប់សំរាប់ពួកយើងអនុវត្តក្នុងជីវភាពប្រចាំថ្ងៃទៅហើយ។

ពួកយើងពេញចិត្តនឹងធ្វើការងារទាំងនេះដើម្បីជួយដល់ក្រុមគ្រួសាររកលុយដោះស្រាយជីវភាព ចង់ទំលាប់ខ្លួនជាមួយការងារមិនចង់ទុកពេលវេលាឱ្យកន្លងផុតដោយឥតប្រយោជន៍ ហើយរៀនរកលុយដោយខ្លួនឯងដែលកើតចេញពីញើសឈាមរបស់ខ្លួន និងចង់បន្តការសិក្សាឱ្យជ្រៅជ្រះមានការងារធ្វើជួយដល់ក្រុមគ្រួសារកុំឱ្យលំបាកដូចសព្វថ្ងៃទៀត៕

*ដកស្រង់ចេញពី កម្ពុជាថ្មី លេខ៨១០*
*ថ្ងៃទី១៤_១៥_សីហា_០៥*

# វាសនាក្មេងអ្នកដើរសុំទាននៅខេត្តតាកែវ

មានក្មេងៗប្រុសស្រីច្រើននាក់ណាស់ដើរ សុំស្រូវ អង្ករ លុយនៅតាមភូមិឃុំ និងនៅតាមផ្សារមួយចំនួន នៅទូទាំងខេត្តតាកែវ ជាក់ស្តែងដូចជាមានក្មេងមួយក្រុមដែលមានគ្នាចំនួន៥នាក់នេះកំពុងតែសុំទានស្រូវ អង្ករនៅតាមផ្ទះប្រជាពលរដ្ឋនៅស្រុកដូនកែវដែលមានឈ្មោះ១.សាត់ ស៊ីណា ភេទស្រី អាយុ ១៥ឆ្នាំ រស់នៅភូមិតាសឹង ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ២.ឈ្មោះអៀប ពៅ ភេទស្រី អាយុ១៣ឆ្នាំ ៣.ឈ្មោះនី ម៉ៅ ភេទស្រី អាយុ១៣ឆ្នាំ ៤.ឈ្មោះថាន់ ងើយ ភេទស្រីអាយុ១៤ឆ្នាំ និង៥.ឈ្មោះសុន ម៉យ ភេទប្រុស អាយុ១៣ឆ្នាំ អ្នកទាំងអស់រស់ក្នុងភូមិជាមួយគ្នា។

ក្មេងស្រីឈ្មោះ សាត់ ស៊ីណា ជាអ្នកតំណាងឱ្យពួកគេបានប្រាប់កម្ពុជាថ្មីថា ខ្ញុំសព្វថ្ងៃរស់នៅគ្មានឪពុកទេ គឺរស់ជាមួយម្តាយ គ្មានស្រែធ្វើនឹងគេទេដោយសារម្តាយខ្ញុំបានលក់មើលជំងឺឪពុកខ្ញុំអស់ហើយ។ គាត់បានស្លាប់ទាំងបិទភ្នែកមិនជិតដោយបន្សល់ទុកកូន និងប្រពន្ធដែលរស់នៅលំបាកវេទនា។

ក្មួយស្រីបន្តថា ចាប់តាំងពីពេលនោះមកគ្រួសាររបស់ក្មួយបានធ្លាក់ខ្លួនយ៉ាប់យ៉ឺន ដុនដាបជាទីបំផុត តំរូវឱ្យបងប្អូននាងខ្ញុំតូចៗទាំងអស់ ត្រូវតែដើរសុំទាន និងស៊ីឈ្នួលគេដើម្បីរកប្រាក់ចិញ្ចឹមជីវិត ។ ប្រការសំខាន់មួយទៀត គឺម្តាយក្មួយបានធ្លាក់ខ្លួនឈឺបន្តទៀតបណ្តាលឱ្យជាបន្ទុកដ៏ធ្ងន់ធ្ងរសំរាប់គ្រួសារក្មួយ។ ការដែលដើរសុំទានក្មួយខ្មាស់គេខ្លាំងណាស់ ប៉ុន្តែកាលៈទេសៈតំរូវឱ្យធ្វើដូច្នេះ ហើយក្មួយត្រូវចំណាយពេលពីព្រឹកទល់ល្ងាចស្ទើររកប្រាក់ទិញអង្ករហូបមិនបានផងនេះគឺមិនទាន់គិតដល់ម្តាយឈឺនៅផ្ទះគ្មានលុយមួយរៀលសោះ។

ចុងបញ្ចប់ក្មួយសូមអំពាវនាវដល់សប្បុរសជន និងអង្គការនានាមេត្តាជួយជ្រោមជ្រែងពួកក្មួយផង ដើម្បីឱ្យពួកក្មួយមានលទ្ធភាពចិញ្ចឹមជីវិត និងប្រកបរបរដូចមនុស្សដែលរស់នៅក្នុងសង្គមថ្លៃថ្នូរនឹងគេ៕

*ដកស្រង់ចេញពី កម្ពុជាថ្មី លេខ៨០៨*
*ថ្ងៃទី១២_០៨_០៥*

# ខេត្តព្រៃវែងប្រជាពលរដ្ឋជាង៦ម៉ឺននាក់ធ្វើចំណាកស្រុកទៅរកការងារធ្វើ

មន្ត្រីទទួលបន្ទុកផ្នែកការងារពលកម្មប្រចាំខេត្តព្រៃវែងបានឱ្យដឹងថាមានប្រជាពលរដ្ឋជាង៦ម៉ឺននាក់បានធ្វើចំណាកស្រុកទៅរកការងារធ្វើខាងក្រៅ ក្នុងនោះមានកុមារជាង៦០០០នាក់។

លោកយិន សារឿន ប្រធានមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តព្រៃវែងបានប្រាប់រស្មីកម្ពុជាតាមទូរស័ព្ទនារសៀលថ្ងៃទី១២ សីហា ២០០៥ថា តួលេខនេះផ្អែកទៅលើការចុះស្រង់ស្ថិតិដែលបានធ្វើឡើងនៅចុងឆ្នាំ២០០៣។ បើគិតរហូតមកដល់ពេលនេះតាមការប៉ាន់ប្រមាណចំនួនប្រជាពលរដ្ឋធ្វើចំណាកស្រុកមានការកើនឡើងបន្ថែមទៀតដោយសារគ្រោះធម្មជាតិកើតឡើងជាប់ៗគ្នារយៈពេលចុងក្រោយនេះ។ ប្រជាពលរដ្ឋដែលធ្វើចំណាកស្រុកច្រើនជាងគេ គឺនៅស្រុកពារាំងនិងស្រុកព្រៃវែង ។ ប្រជាពលរដ្ឋទាំងនោះធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃ រាជធានីភ្នំពេញ ក្រុងព្រះសីហនុ ខេត្តកោះកុង និងខេត្តបន្ទាយមានជ័យ។

លោកសារឿនបន្ថែមទៀតថា កត្តាដែលជំរុញឱ្យប្រជាពលរដ្ឋធ្វើចំណាកស្រុកនេះដោយសារតែខេត្តព្រៃវែងជាខេត្តមួយដែលប្រជាពលរដ្ឋមានរបរកសិកម្មជាសំខាន់ គ្មានរបរអ្វីផ្សេងទៀត។ នៅពេលជួបគ្រោះធម្មជាតិធ្វើឱ្យពួកគេជួបការខ្វះខាតក្នុងជីវភាពជំរុញឱ្យពួកគេត្រូវធ្វើចំណាកស្រុក។

លោក ប៉ែន អ៊ាន អភិបាលរងខេត្តព្រៃវែងមានប្រសាសន៍ថា ដើម្បីបញ្ចៀសប្រជាពលរដ្ឋកុំឱ្យធ្វើចំណាកស្រុកនោះ វាជាបញ្ហាធំណាស់ មិនមែនដោះស្រាយមួយថ្ងៃបាននោះទេ វាត្រូវការពេលវេលាយូរ ហើយបញ្ហាចំណាកស្រុកនេះវាមានគ្រប់ខេត្ត គ្រាន់តែតិចរឺច្រើនប៉ុណ្ណោះ ។ កន្លងមកលោកអភិបាលរងតែងតែចុះតាមមូលដ្ឋានដើម្បីពង្រឹងសតិអារម្មណ៍ប្រជាពលរដ្ឋ និងបានពន្យល់ពីផលប៉ះពាល់ និងគ្រោះថ្នាក់មួយចំនួនពីការធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃ ប៉ុន្តែនៅតែមិនអាចទប់ស្កាត់បានដោយសារតែការអត់ឃ្លានបង្កឡើងដោយគ្រោះធម្មជាតិ។

លោកប៉ែន អ៊ាន បានបញ្ជាក់ថា ប្រសិនបើប្រជាពលរដ្ឋអាចបង្កបង្កើតផលបាននៅក្នុងភូមិស្រុករបស់ខ្លួន ពួកគេប្រាកដជាពុំធ្វើចំណាកស្រុកនោះទេ។ ដូច្នេះដើម្បីកាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋនោះត្រូវប្រែក្លាយខេត្តព្រៃវែងជាតំបន់សេដ្ឋកិច្ច៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៥២*
*ថ្ងៃទី១៣_០៨_០៥*

# ដេកគុកដោយសារសើយសំពត់កូនស្រី និងប្រើអំពើហិង្សាលើភរិយា

បុរសម្នាក់ត្រូវប៉ូលិសចាប់ខ្លួន បន្ទាប់ពីបានប្រព្រឹត្តអំពើមិនគប្បីដោយសើយសំពត់កូនស្រី និងយកកាំបិតកាប់សំពងលើប្រពន្ធរបស់ខ្លួន បណ្ដាលឱ្យរងរបួសជាទំងន់។

ប្រភពព័ត៌មាននៅកន្លែងកើតហេតុបានឱ្យដឹងថា អំពើហិង្សានេះកើតឡើងនៅវេលាម៉ោង៨ និង៥នាទីយប់ថ្ងៃទី១៤ សីហា ២០០៥កន្លងមកនេះ នៅភូមិចុងព្រែក ឃុំចុងព្រែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល។

ឪពុកកំហូចដែលប៉ូលិសចាប់ខ្លួនពីបទប្រព្រឹត្តអំពើមិនគប្បីមកលើកូនស្រី និងប្រើអំពើហិង្សាមកលើភរិយារបស់ខ្លួននោះឈ្មោះជ.ង អាយុ៣៧ឆ្នាំ។ រីឯ ក្មេងស្រីរងគ្រោះឈ្មោះជ.វ អាយុ១៦ឆ្នាំ និងស្ត្រីរងគ្រោះដែលត្រូវស្វាមីប្រើអំពើហិង្សាមកលើរាងកាយនោះឈ្មោះយាន អាយុ៣៦ឆ្នាំ។ ទាំងបីនាក់ឪពុកកូន និងភរិយាស្នាក់នៅភូមិចុងព្រែក ឃុំព្រែកឯង ស្រុកកៀនស្វាយ។

ប្រភពព័ត៌មានដដែលបានបន្តថា នាយប់នោះគេបានឃើញក្មេងស្រីរងគ្រោះដើរឡើងទៅលើផ្ទះ។ ពេលនោះឪពុកកំហូចបានយកដៃទៅសោយលាត់សំពត់កូនស្រីរបស់ខ្លួនក្នុងបំណងមិនល្អសោះធ្វើឱ្យក្មេងស្រីស្រែកឡើង ដោយការមិនពេញចិត្ត ហើយភ្លាមនោះម្ដាយកុមារីក៏ឃើញហេតុការណ៍អាក្រក់នេះដែរ រួចដើរមកជួយកូនស្រីរបស់ខ្លួន ពេលនោះបុរសកំហូចក៏ខឹងក៏ស្ទុះទាញយកកាំបិតមកកាប់សំពងទៅលើប្រពន្ធបណ្ដាលឱ្យត្រូវដៃរបួសយ៉ាងធ្ងន់ធ្ងរ។

ស្ត្រីជាភរិយាដោយទ្រាំទ្រពុំបានចំពោះអំពើដ៏លាមកនេះ ក៏ប្ដឹងប៉ូលិសមូលដ្ឋានឱ្យចាប់ស្វាមីឃោរឃៅរបស់ខ្លួនមកញាត់ទ្រុងនៅអធិការដ្ឋានប៉ូលិសស្រុកកៀនស្វាយទាំងយប់។

ប្រភពដដែលបានបន្តទៀតថា កាលពីឆ្នាំ២០០៤ បុរសកំហូចរូបនេះធ្លាប់បានប្រព្រឹត្តអំពើមិនគប្បីមកលើកូនស្រីរបស់ខ្លួននោះម្ដងរួចមកហើយ នេះជាលើកទី២ដែលគេប្រព្រឹត្ត ប៉ុន្តែបុរសកំហូចនេះគេបានបកស្រាយថា នាយប់នោះរូបគេស្រវឹងស្រា ហើយក៏ប្រព្រឹត្តយ៉ាងនេះស្មានតែជាភរិយារបស់ខ្លួន មិននឹកស្មានថាជាកូនសោះ។ ទោះបីបុរសនេះខំបកស្រាយយ៉ាងណាក៏ដោយ ក៏ប៉ូលិសអះអាងថា នេះជាពាក្យដោះសារប៉ុណ្ណោះ។ ប៉ូលិលបានកសាងសំណុំរឿងបញ្ជូនមកតុលាការខេត្តកណ្ដាលដើម្បីវិនិច្ឆ័យទោសតាមច្បាប់៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៥៤*
*ថ្ងៃទី១៦_០៨_០៥*

# ទារលុយប្រពន្ធ៣០$មិនបានចាប់ទាំងប្រពន្ធ និងកូនពីរនាក់ចងផ្អោបដើមព្រីង

អំពើហិង្សាមិនចាំបាច់តែវាយធ្វើបាប ឬបង្កឱ្យមានរបួសស្នាមដល់អ្នកដទៃគ្រាន់តែប្រើអំពើហិង្សាវាយប្រពន្ធកូនខ្លួនឯងឱ្យមានរបួសស្នាមក៏មានទោសដែរ។

ជាក់ស្ដែងកាលពីវេលាម៉ោង៦ល្ងាច ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៥ បុរសម្នាក់ត្រូវប៉ូលិសរដ្ឋបាលឃុំត្រពាំងវែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ចាប់ខ្លួនពីបទវាយប្រពន្ធកូនខ្លួនឯងឱ្យរបួសយ៉ាងធ្ងន់ធ្ងរ។

ប៉ូលិសមូលដ្ឋានបានប្រាប់ឱ្យដឹងថា ជនជាប់ចោទពីបទវាយប្រពន្ធកូនខ្លួនឯងនេះមានឈ្មោះធឿន កំសត់អាយុ៤០ឆ្នាំមានទីលំនៅភូមិព្រៃទទឹង ឃុំត្រពាំងវែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ចំណែកជនរងគ្រោះ(ប្រពន្ធ)ឈ្មោះឡូតគីម អាយុ៣៤ឆ្នាំ កូនប្រុសឈ្មោះនូស្ដួស្ដី អាយុ១០ឆ្នាំនិងកូនស្រីអាយុ៨ឆ្នាំរស់នៅក្នុងបន្ទុកឪពុកម្ដាយ។

បើតាមសំដីស្ត្រីរងគ្រោះជាប្រពន្ធបានប្រាប់ប៉ូលិសឱ្យដឹងថា កន្លងមកប្ដីគាត់តែងតែវាយធ្វើបាបលើរូបគាត់ និងកូនជាញឹកញាប់ ព្រោះគាត់មានប្រពន្ធដល់ទៅ២នាក់ឯណោះ។ ពេលមកដល់ម្ដងៗប្ដីគាត់តែងតែទារលុយ បើមិនឱ្យឬគ្មានលុយគាត់តែងតែវាយធ្វើបាបគ្មានអ្នកណាហ៊ានចេញមុខចូលឃាត់ឡើយ។ ហើយកាលពីវេលាម៉ោង៦ល្ងាច ថ្ងៃទី១៤ ខែសីហា ប្ដីគាត់បានមកផ្ទះទារលុយចំនួន៣០$តែគាត់គ្មានលុយឱ្យស្រាប់តែប្ដីគាត់ចាប់វាយធ្វើទារុណកម្មលើរូបគាត់ និងកូនទាំងពីរនាក់ចងផ្អោបជាប់ដើមព្រីងរួចយកដំបងវាយធ្វើបាបតាមកំហឹងរបស់គាត់ជាប្ដី។

ដោយឃើញយ៉ាងអាណោចអាធ័មខ្លាំងពេកប្រជាពលរដ្ឋបានលួចរាយការណ៍

តទៅទំព័រទី៨

*តមកពីទំព័រទី៧*

ប្រាប់ប៉ូលិសមូលដ្ឋានឱ្យមកជួយ បើមិនដូច្នេះប្តីកំណាចមុខលុយនេះអាចវាយធ្វើបាបប្រពន្ធកូនខ្លួនរហូតដល់ស្លាប់។ ភ្លាមនោះប៉ូលិសមូលដ្ឋានបានមកដល់កន្លែងកើតហេតុភ្លាមនៅពេលបុរសជាប្តីកំពុងវាយធ្វើបាបប្រពន្ធកូនចងផ្ទោបដើមព្រីងមុខផ្ទះរបស់ខ្លួនដោយគ្មាននរណាហ៊ានចូលឃាត់ឡើយ។

ពេលនេះសមត្ថកិច្ចប៉ូលិសខេត្តកណ្តាលកំពុងរៀបចំកសាងសំណុំរឿងបញ្ជូនជនជាប់ចោទឡើងតុលាការដើម្បីធ្វើការចោទប្រកាន់តាមច្បាប់៕

*ដកស្រង់ចេញពី កម្ពុជាថ្មី លេខ៨១២*
*ថ្ងៃទី១៧_០៨_០៥*

# គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ
# NGO Committee on the Rights of the Child

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ( គ. អ. ស. ក) ជាសម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលមួយដែលមានអង្គការជាសមាជិកចំនួន៤០។ គ. អ. ស. ក មានតួនាទីធ្វើការលើកកំពស់ការយល់ដឹងអំពីសិទ្ធិកុមារ ធ្វើការងារតស៊ូមតិ និងតាមដានការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា។

ដោយយល់ឃើញពីតំរូវការចាំបាច់នៃការប្រមូលផ្តុំ ចងក្រង និងផ្សព្វផ្សាយព័ត៌មាននានាដែលទាក់ទងនឹងកុមារនៅក្នុងប្រទេសកម្ពុជា ទើបគ. អ. ស. ករៀបចំសំរង់ព័ត៌មានប្រចាំសប្តាហ៍នេះដែលជាការដកស្រង់ពត៌មានទាក់ទងនឹងកុមារពីអត្ថបទនៃបណ្តាសារព័ត៌មាននានាដែលវាពុំមែនជាគំនិត ឬទស្សនៈរបស់គ. អ. ស. កទេ។

អាសយដ្ឋានទំនាក់ទំនង: ផ្ទះកុមារ លេខ៨A ផ្លូវ១៣៨ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទ : (៨៥៥) ២៣ ៨៨២ ៤១២

ទូរសារ : (៨៥៥) ២៣ ៨៨២ ៤១២

អ៊ីមែល : ch.ngocrc@online.com.kh